# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ 004/04 គ.ជ.ប**

## សេចក្តីប្រកាស

### ឯកឧត្តម ជិន គឹមស្រេង បេក្ខជនតំណាងរាស្ត្រលំដាប់ទី ៩ របស់គណបក្សប្រជាជនកម្ពុជា នៅមណ្ឌលខេត្ត កំពង់ចាម

### គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម នស/រកម/១២៩៧.០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម ជស/រកម/១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០២/៣០០ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០២ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៣ ។
- បានឃើញសេចក្តីសម្រេចលេខ ០៥.២៣២/០៣ គ.ជ.ប. ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្តីសម្រេចលេខ ០៨.៥១៧/០៣ គ.ជ.ប. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិ ទី ៣ ។
- បានឃើញលិខិតលេខ ៤៨៨ លគ.គក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៤ ស្តីពីការសុំប្រកាសទទួលស្គាល់ឯកឧត្តម **ចិន គឹមស្រេង** ជំនួសឯកឧត្តម **ម៉ាត់ លី** បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនៃគណបក្ស **ប្រជាជនកម្ពុជា** ។
- បានឃើញសេចក្តីសម្រេចលេខ 003/04 គ.ជ.ប. ចុះថ្ងៃទី 23 ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការលុបឈ្មោះឯកឧត្តម **ម៉ាត់ លី** ចេញពីបញ្ជីបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស **ប្រជាជនកម្ពុជា** មណ្ឌលខេត្ត **កំពង់ចាម** ។

### ប្រកាស

**ប្រការ១** : ឯកឧត្តម **ជិន គឹមស្រេង** ភេទ ប្រុស អាយុ ៦៣ ឆ្នាំ ជាបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត គណបក្ស **ប្រជាជនកម្ពុជា** មណ្ឌលខេត្ត **កំពង់ចាម** ។

**ប្រការ២** : គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣** : សេចក្តីសម្រេចនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី 23 ខែ មីនា ឆ្នាំ ២០០៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**អ៊ឹម សួស្ដី**

**ចម្លងគោរពជូន**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- មជ្ឈមណ្ឌលតំកល់ឯកសារជាតិ
- គណបក្សនយោបាយ " ដើម្បីជូនជ្រាប "
- ដូចប្រការ ២ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ